# ការធ្វើតេស្តរកមើល COVID-19

## តើខ្ញុំគួរធ្វើតេស្តរកមើល COVID-19 នៅពេលណា?



- អ្នកមានរោគសញ្ញា COVID-19។
- អ្នកមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ ហើយថ្មីៗនេះបានប៉ះពាល់ជាមួយនរណាម្នាក់ដែលមាន COVID-19។
- អ្នកគឺជាអ្នកទំនាក់ទំនងគ្រួសារ ឬមានការប្រឈមមុខនឹងហានិភ័យខ្ពស់ ឬមធ្យម ជាមួយនរណាម្នាក់ដែលមាន COVID-19។

## តើអ្នកណាដែលមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ?

- មនុស្សដែលមានអាយុ៦០ឆ្នាំ និងអាយុលើសនេះ
- ស្ត្រីមានផ្ទៃពោះ
- ជនជាតិដើមភាគតិច អ្នកកោះ Torres Strait និងអ្នកកោះប៉ាស៊ីហ្វិក (ចាប់ពីអាយុ៣៥ឆ្នាំ និងអាយុលើសនេះ)
- អ្នកដែលមានជំងឺធាត់ ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមបេះដូងធ្ងន់ធ្ងរ ជំងឺសួតរ៉ាំរ៉ៃ *(រួមទាំងជំងឺហឺតធ្ងន់ធ្ងរដែលតម្រូវឱ្យចូលព្យាបាលនៅមន្ទីរពេទ្យ ក្នុងរយៈពេល១២ខែចុងក្រោយ)* ជំងឺថ្លើមរ៉ាំរ៉ៃធ្ងន់ធ្ងរ ឬជំងឺតម្រងនោម ជំងឺមហារីកសកម្ម ឬអ្នកដែលមានភាពស៊ាំចុះខ្សោយ
- មនុស្សមួយចំនួនដែលមានពិការភាព រួមមានជនពិការដែលប៉ះពាល់ដល់សួត បេះដូង ឬប្រព័ន្ធភាពស៊ាំរបស់ពួកគេ
- អ្នករស់នៅក្នុងមណ្ឌលថែទាំមនុស្សចាស់ និងថែទាំមនុស្សពិការ
- មនុស្សដែលមានអាយុ១៨ឆ្នាំ និងអាយុលើសនេះ ដែលមិនបានចាក់វ៉ាក់សាំង

## តើការធ្វើតេស្តរកមើល COVID-19 អ្វីដែលខ្ញុំគួរនឹងទទួលបាន?



មាន**ការធ្វើតេស្តពីរផ្សេងគ្នា**ដែលអ្នកអាចទទួលបាន ដើម្បីពិនិត្យមើលថាតើអ្នកមាន COVID-19 ឬអត់។ **ការធ្វើតេស្តអង់ទីហ្សែនរហ័ស** (RAT) ដែលអ្នកអាចធ្វើបានដោយខ្លួនឯង និង**ការធ្វើតេស្ត PCR** (តម្បារទាញយកវត្ថុរាវពីក្នុងច្រមុះ និងបំពង់ក) ដែលធ្វើនៅគ្លីនិកធ្វើតេស្ត

- **ប្រសិនបើអ្នកមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ** អ្នកគួរតែ**ធ្វើតេស្ត PCR**។ ប្រសិនបើអ្នកមិនអាចទទួលបានលទ្ធផលតេស្ត PCR យ៉ាងឆាប់រហ័សទេ សូមធ្វើតេស្តអង់ទីហ្សែនរហ័ស (ប្រសិនបើអ្នកមាន) ខណៈពេលដែលអ្នករង់ចាំលទ្ធផលតេស្ត PCR។
- ប្រសិនបើអ្នកមិនមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរទេ សូមធ្វើតេស្តអង់ទីហ្សែនរហ័ស លុះត្រាតែវេជ្ជបណ្ឌិតរបស់អ្នកប្រាប់អ្នកឱ្យធ្វើតេស្ត PCR។

## តើខ្ញុំធ្វើដូចម្តេចប្រសិនបើខ្ញុំធ្វើតេស្តវិជ្ជមាន COVID-19?




- ប្រសិនបើអ្នកមានលទ្ធផលតេស្ត **PCR វិជ្ជមាន** ទោះបីជាអ្នកមិនមានរោគសញ្ញានានាក៏ដោយ នោះអ្នកមាន COVID-19 ហើយ។ អ្នកត្រូវតែធ្វើតាមដំបូន្មានសម្រាប់មនុស្សដែលធ្វើតេស្តវិជ្ជមាន COVID-19 និងការគ្រប់គ្រង COVID-19 ដោយសុវត្ថិភាពនៅផ្ទះ។
- ប្រសិនបើអ្នកមានការធ្វើតេស្តអង់ទីហ្សែនរហ័សវិជ្ជមាន **សូមចុះបញ្ជីលទ្ធផលជាមួយ Service NSW** ហើយធ្វើតាមដំបូន្មានសម្រាប់មនុស្សដែលធ្វើតេស្តវិជ្ជមាន COVID-19 និងការគ្រប់គ្រង COVID-19 ដោយសុវត្ថិភាពនៅផ្ទះ។

ប្រសិនបើមានការព្រួយបារម្ភអំពីសុខភាពណាមួយ ហើយត្រូវការជំនួយផ្នែកភាសា សូមទូរសព្ទទៅ **TIS** តាមលេខ **131 450** ហើយស្នើសុំ Health Direct តាមទូរសព្ទលេខ **1800 022 222**។



© NSW Health June 2022.